# **សូមដោយចិត្តជឿ**

អែលឌើរ ដេវីឌ អេ បែដណា
នៃក្រុមសាវក 12 នាក់

*ការអធិស្ឋានដែលមានអត្ថន័យតំរូវឱ្យមានទាំងការប្រាស្រ័យទាក់ទងបរិសុទ្ធ និងកិច្ចការដែលបានតែងតាំង ។*

ខ្ញុំសូមព្រះវិញ្ញាណបរិសុទ្ធឱ្យជួយយើងទាំងអស់ នៅពេលដែលយើងពិចារណានូវគោលការណ៍មួយ ដែលអាចជួយដល់ការអធិស្ឋានរបស់យើងឱ្យប្រែក្លាយកាន់តែមានអត្ថន័យ--- ជាគោលការណ៍ដំណឹងល្អនៃការសូមដោយចិត្ត ជឿ ។

ខ្ញុំចង់រំឭកឡើងវិញនូវគំរូចំនួនបីស្ដីពីការសូមដោយចិត្តជឿនៅក្នុងការអធិស្ឋានប្រកបដោយអត្ថន័យ និងពិភាក្សានូវមេរៀនទាំងឡាយដែលយើងអាចរៀនពីមេរៀននីមួយៗ ។ នៅពេលយើងនិយាយអំពីការអធិស្ឋាន ខ្ញុំសូមសង្កត់ធ្ងន់នូវពាក្យថា *ដែលមានអត្ថន័យ*។ ជាធម្មតា ការពោលពាក្យអធិស្ឋាន គឺជារឿងដែលខុសប្លែកពីការធ្វើនៅក្នុងការអធិស្ឋានដែលមានអត្ថន័យ ។ ខ្ញុំសង្ឃឹមថាយើងគ្រប់រូបបានដឹងរួចជាស្រេចថា ការអធិស្ឋានគឺវិសេសវិសាលសំរាប់ការរីកចំរើនខាងវិញ្ញាណ និងការការពាររបស់យើង ។ ប៉ុន្តែអ្វីដែលយើងដឹង ជានិច្ចកាលពុំត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអ្វីដែលយើងធ្វើនោះទេ ។ ហើយទោះបីជាយើងដឹងនូវសារៈសំខាន់នៃការអធិស្ឋានក៏ដោយ ក៏យើងទាំងអស់គ្នាអាចធ្វើឱ្យមានភាពមាំមួន និងភាពសក្តិសិទ្ធិក្នុងការអធិស្ឋានផ្ទាល់ខ្លួន និងជាគ្រួសាររបស់យើងកាន់តែប្រសើរឡើងដែរ ។

## **សូមដោយចិត្តជឿ ហើយធ្វើតាម**

គំរូដ៏សាមញ្ញនៃការសូមដោយចិត្តជឿ គឺលោក យ៉ូសែប ស្ម៊ីធ និងការនិមិត្តដំបូង ។ នៅពេលដែល យ៉ូសែប នៅវ័យក្មេងកំពុងស្វែងរកដើម្បីឱ្យដឹងនូវសេចក្ដីពិតអំពីសាសនា លោកបានអាននូវខគម្ពីរនៅក្នុងយ៉ាកុប ជំពូកទីមួយដូចខាងក្រោមនេះ :

"បើអ្នករាល់ណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធាឥតបន្ទោសផង នោះទ្រង់នឹងប្រទានឱ្យ ។

"តែត្រូវឱ្យអ្នកនោះសូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ" (យ៉ាកុប 1:5--6) ។

សូមកត់សំគាល់នូវតំរូវការដើម្បីសូមដោយចិត្តជឿ ដែលខ្ញុំចង់សង្កត់ន័យនូវការចាំបាច់ដោយមិនគ្រាន់តែសម្ដែងឡើងប៉ុណ្ណោះទេ ប៉ុន្តែធ្វើវាជាកាតព្វកិច្ចទ្វេទាំងការទូលអង្វរ និងការអនុវត្តជាតំរូវការដើម្បីប្រាស្រ័យទាក់ទង ហើយធ្វើតាម ។

ការសញ្ជឹងគិតនូវអត្ថបទនៃព្រះគម្ពីរប៊ីបនេះបាននាំលោក យ៉ូសែប ទៅកាន់ព្រៃមួយនៅក្បែរផ្ទះរបស់លោកដើម្បីអធិស្ឋាន និងស្វែងរកនូវចំណេះដឹងខាងវិញ្ញាណ ។ សូមកត់ចំណាំត្រង់សំណួរដែលបានដឹកនាំគំនិត និងការបួងសួងរបស់លោក យ៉ូសែប ។

"នៅកណ្ដាលចំបាំងខាងពាក្យសំដី និងការជ្រួលច្របល់ខាងគំនិតជឿនេះ ខ្ញុំតែងតែគិតក្នុងចិត្តខ្ញុំថា: តើត្រូវធ្វើអ្វីហ្ន៎? តើបក្សពួកមួយណាទៅដែលត្រូវ ឬក៏គេសុទ្ធតែខុសទាំងអស់គ្នា? បើសិនជាបក្សពួកណាមួយដែលត្រូវ តើណាមួយទៅ ហើយតើខ្ញុំនឹងស្គាល់តាមរបៀបណាបាន?...

"គោលបំណងរបស់ខ្ញុំ ក្នុងការទៅទូលដល់ព្រះអម្ចាស់គឺចង់ដឹងថា បក្សពួកណាមួយទៅដែលត្រូវ ដើម្បីខ្ញុំបានដឹងថា ខ្ញុំត្រូវចូលរួមនឹងបក្សណាមួយ" (យ៉ូសែប ស្ម៊ីធ---ប្រវត្តិ 1:10, 18)។

សំណួររបស់លោកយ៉ូសែប មិនត្រឹមតែផ្ដោតយកចិត្តទុកដាក់ទៅលើអ្វីដែលលោកត្រូវការដឹងទេ ប៉ុន្តែទៅលើអ្វីដែលត្រូវ *ធ្វើឱ្យសំរេច* ផងដែរ! ការអធិស្ឋានរបស់លោកមិនធម្មតាទេ: តើព្រះវិហារណាមួយត្រូវ? សំណួររបស់លោកគឺ: តើព្រះវិហារមួយណាដែលខ្ញុំគួរតែចូលរួម? លោកយ៉ូសែប បានទៅក្នុងព្រៃដើម្បីសួរដោយសេចក្ដីជំនឿ ហើយលោកបានប្ដេជ្ញាចិត្តដើម្បីអនុវត្តតាម។

សេចក្ដីជំនឿពិតគឺផ្ដោតយកចិត្តទុកដាក់នៅក្នុង និងនៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយតែងតែដឹកនាំទៅរកសកម្មភាពសុចរិត។ ព្យាការីយ៉ូសែប បានបង្រៀនថា "សេចក្ដីជំនឿ [គឺជា] គោលការណ៍ទីមួយ នៅក្នុងសាសនាចក្រដែលបានបើកសម្ដែង ហើយជាគ្រឹះនៃរាល់សេចក្ដីសុចរិត" ហើយថាវាក៏ជា "គោលការណ៍នៃ ការអនុវត្តន៍នៅក្នុងបុគ្គលដែលមានបញ្ញាទាំងអស់" (*Lectures on Faith* [1985], 1)។ ការអនុវត្តន៍តែមួយមុខ គឺមិនមែនជាសេចក្ដីជំនឿនៅលើព្រះអង្គសង្គ្រោះឡើយ ប៉ុន្តែជាការអនុវត្តន៍ដែលស្របជាមួយនឹងគោលការណ៍ត្រឹមត្រូវគឺជាសមាសភាពដ៏សំខាន់នៃសេចក្ដីជំនឿ។ ហេតុដូច្នេះហើយ "សេចក្ដីជំនឿដែលឥតមានការប្រព្រឹត្ត នោះឈ្មោះថាស្លាប់ហើយ" (យ៉ាកុប 2:20)។

ព្យាការី យ៉ូសែប បានពន្យល់ថែមទៀតថា: "សេចក្ដីជំនឿមិនមែនគ្រាន់តែជាគោលការណ៍ នៃការអនុវត្តន៍ប៉ុណ្ណោះទេ ប៉ុន្តែជាអំណាចផងដែរ នៅក្នុងមនុស្សដែលមានបញ្ញាទាំងអស់ មិនថានៅស្ថានសួគ៌ ឬនៅលើផែនដីទេ" (*Lectures on Faith* ទំព័រ 3)។ ហេតុដូច្នេះហើយ សេចក្ដីជំនឿលើព្រះគ្រីស្ទ ដឹកនាំទៅរកការអនុវត្តន៍ដែលសុចរិតដែលបង្កើនសមត្ថភាព និងអំណាចខាងវិញ្ញាណរបស់យើង។ ការយល់ដឹងថា សេចក្ដីជំនឿគឺជាគោលការណ៍នៃការអនុវត្តន៍ និងអំណាចនៃការបំផុសគំនិតដល់យើង ឱ្យអនុវត្តន៍សិទ្ធិជ្រើសរើសខាងសីលធម៌ នៅក្នុងការប្រព្រឹត្តតាមជាមួយនឹងគោលការណ៍ដំណឹងល្អពិត អញ្ជើញឱ្យការប្រោសលោះ និង កម្លាំងនៃ *ព្រះចេស្ដា* នៃដង្វាយធួនរបស់ព្រះអង្គ-សង្គ្រោះ មកគង់នៅក្នុងជីវិតរបស់យើង និងពង្រីក *ព្រះចេស្ដា* នៅជាមួយយើង ហេតុដូច្នោះហើយយើងគឺជាភ្នាក់ងារចំពោះខ្លួនរបស់យើងផ្ទាល់ (សូមមើល គ. និង ស. 58:28)។

ខ្ញុំបានមានចំណាប់អារម្មណ៍ជាយូរមកហើយ ជាមួយនឹងសេចក្ដីពិតដែលថាការអធិស្ឋានដែលមានអត្ថន័យ តំរូវឱ្យមានទាំងការប្រាស្រ័យទាក់ទងបរិសុទ្ធ និងកិច្ចការដែលបានតែងតាំង។ ពរជ័យទាំងឡាយតំរូវឱ្យមាននូវការខិតខំប្រឹងប្រែង ខ្លះៗពីយើងទាំងអស់គ្នា ពីមុនយើងអាចទទួលពរជ័យទាំងនោះ ហើយការអធិស្ឋានដូចជា "បែបបទការងារ ... ការអធិស្ឋានគឺជាមធ្យោបាយដែលបានតាំងឡើងមួយដើម្បីទទួលបាននូវកិរិតដ៏ខ្ពស់បំផុតនៃពរជ័យទាំងអស់" (សូមមើល Bible Dictionary "Prayer" 753)។ យើងឈានទៅមុខ ហើយតស៊ូនៅក្នុងកិច្ចការដែលបានតែងតាំង នៃការអធិស្ឋាន បន្ទាប់ពីយើងពោលពាក្យថា "អាម៉ែន" ដោយធ្វើតាមនូវរឿងទាំងឡាយដែលយើងបានបង្ហាញទៅកាន់ព្រះវរបិតាសួគ៌។

ការសូមដោយចិត្តជឿតំរូវឱ្យមាននូវភាពស្មោះត្រង់ ការប្រឹងប្រែង ការតាំងចិត្ត និងការតស៊ូ។ ខ្ញុំសូមផ្ដល់នូវការបញ្ជាក់មួយអំពីអ្វីដែលខ្ញុំចង់មានន័យ និងធ្វើនូវការអញ្ជើញមួយដល់អ្នកទាំងអស់គ្នា។

យើងអធិស្ឋានដោយត្រឹមត្រូវសំរាប់សុវត្ថិភាព និងជោគជ័យនៃអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងទូទាំងពិភពលោក។ ហើយធាតុដ៏សំខាន់មួយនៅក្នុងការអធិស្ឋានដ៏ច្រើនរបស់យើង គឺជាការស្នើសុំមួយថាអ្នកផ្សព្វផ្សាយទាំងឡាយនឹងត្រូវបានដឹកនាំទៅកាន់បុគ្គល និងក្រុមគ្រួសារទាំងឡាយដែលត្រូវបានរៀបចំឱ្យទទួលនូវសារលិខិត នៃការស្តារឡើងវិញ។ ប៉ុន្តែនៅទីបំផុតកិច្ចការនេះគឺជាការទទួលខុសត្រូវរបស់ខ្ញុំ និងជាការទទួលខុសត្រូវរបស់អ្នកទាំងអស់គ្នា ដើម្បីស្វែងរកមនុស្សសំរាប់អ្នកផ្សព្វផ្សាយសាសនាដើម្បីបង្រៀន។ អ្នកផ្សព្វផ្សាយសាសនា គឺជាគ្រូបង្រៀនពេញម៉ោង អ្នកទាំងអស់គ្នា ហើយនិងរូបខ្ញុំគឺជាស្វែងរកពេញម៉ោង។ ហើយអ្នកទាំងអស់គ្នា និងរូបខ្ញុំ ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាដ៏យូរអង្វែងពុំគប្បីអធិស្ឋានដើម្បីឱ្យអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ធ្វើនូវកិច្ចការរបស់យើងឡើយ!

ប្រសិនបើអ្នកទាំងអស់គ្នា និងរូបខ្ញុំនឹងអធិស្ឋានយ៉ាងពិតប្រាកដ ហើយសូមដោយចិត្តជឿ ដូចដែលលោក យ៉ូសែប ស្ម៊ីធ បានធ្វើ---ប្រសិនបើយើងនឹងអធិស្ឋានជាមួយនឹងការរំពឹងទុកដើម្បីធ្វើតាម ហើយដោយពុំមែនគ្រាន់តែបង្ហាញនូវចំណង់របស់យើងនោះទេ--- នោះកិច្ចការនៃការប្រកាសដំណឹងល្អនឹងឈានទៅមុខនៅក្នុងរបៀបដ៏អស្ចារ្យមួយ។ ការអធិស្ឋានមួយប្រកដដោយសេចក្តីជំនឿបែបនេះ ត្រូវមានសមាសភាពខ្លះៗដូចខាងក្រោមនេះ :

• ថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ចំពោះគោលលទ្ធិ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អរបស់ ព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ បាននាំមកនូវសេចក្តីសង្ឃឹម និងសុភមង្គលក្នុងជីវិតរបស់យើង។

• សុំសេចក្តីក្លាហាន និងទំនុកចិត្តដើម្បីបើកមាត់របស់យើង ហើយចែកចាយនូវដំណឹងល្អជាមួយនឹង គ្រួសារ និង មិត្តភក្តិរបស់យើង។

• សុំដោយស្មោះត្រង់ដល់ព្រះវរបិតាសួគ៌ឱ្យជួយយើងឱ្យស្គាល់បុគ្គល និងគ្រួសារទាំងឡាយដែលនឹងព្រមទទួលការអញ្ជើញរបស់យើង ដើម្បីរៀនជាមួយនឹងអ្នកផ្សព្វផ្សាយសាសនានៅក្នុងគេហដ្ឋានរបស់យើង។

• សន្យាដើម្បីធ្វើនូវផ្នែករបស់យើងនៅថ្ងៃនេះ និងសប្តាហ៍នេះ--- និងការទូលអង្វរឱ្យមានជំនួយដើម្បីឈ្នះលើការព្រួយបារម្ភ ការភ័យខ្លាច និងការស្ទាក់ស្ទើរ។

• ស្វែងរកអំណោយទានឱ្យចេះសង្កេត---ដើម្បីឱ្យភ្នែកទាំងគូមើលឃើញ ហើយត្រចៀកស្តាប់ឮនូវឱកាសសំរាប់អ្នកផ្សព្វផ្សាយសាសនា នៅពេលវាកើតមានឡើង។

• អធិស្ឋានយ៉ាងក្លៀវក្លាសំរាប់កម្លាំងដើម្បីធ្វើតាម នៅពេលដែលយើងដឹងថាយើងគួរធ្វើវា។

អំណរគុណនឹងត្រូវបានធ្វើឡើង ហើយពរជ័យផ្សេងទៀតអាចត្រូវបានសុំនៅក្នុងការអធិស្ឋានបែបនេះ--ដែលនឹងត្រូវបានបញ្ចប់ទៅនៅក្នុងព្រះនាមនៃព្រះអង្គសង្គ្រោះ។ ហើយបន្ទាប់មកកិច្ចការដែលបានតែងតាំង នៃការអធិស្ឋាននោះនឹងបន្ត ហើយចំរើនឡើង។

គំរូដូចគ្នានេះនៃការប្រាស្រ័យទាក់ទងបរិសុទ្ធ និងកិច្ចការដែលបានតែងតាំង អាចត្រូវបានអនុវត្តនៅក្នុងការអធិស្ឋានរបស់យើងសំរាប់អ្នកក្រីក្រ និងអ្នកកំសត់ទុគតិ អ្នកឈឺ និងអ្នកដែលរងទុក្ខវេទនា សំរាប់សមាជិកគ្រួសារ និងមិត្តភក្តិដែលកំពុងមានវិបត្តិ និងសំរាប់អ្នកទាំងឡាយណាដែលពុំបានចូលរួមការប្រជុំសាសនាចក្រ។

ខ្ញុំធ្វើទីបន្ទាល់ថា ការអធិស្ឋានប្រែក្លាយជាមានអត្ថន័យបាន នៅពេលយើងសូមដោយចិត្តជឿ ហើយធ្វើតាម។ ខ្ញុំសូមអញ្ជើញយើងទាំងអស់គ្នាឱ្យអធិស្ឋានដោយសេចក្តីជំនឿ អំពីបទបញ្ញត្តិមកពីព្រះមកកាន់យើងទាំងអស់គ្នាថា

យើងគប្បីចែកចាយនូវដំណើងល្អ ។ នៅពេលដែលយើងធ្វើដូចនេះ ខ្ញុំសូមសន្យាថាទ្វារទាំងឡាយនឹងបើកឡើង ហើយយើងនឹងត្រូវប្រទានពរដើម្បីយល់ និងធ្វើតាមចំពោះឱកាសទាំងឡាយដែលនឹងត្រូវបានផ្ដល់ឱ្យ ។

## ក្រោយពីការសាកល្បងនៃសេចក្ដីជំនឿរបស់យើង

គំរូទីពីររបស់ខ្ញុំសង្កត់ន័យលើសារៈសំខាន់នៃការរក្សាទុក តាមរយៈការសាកល្បងនៃសេចក្ដីជំនឿរបស់យើង ។ កាលពីប៉ុន្មានឆ្នាំមុន មានគ្រួសារមួយបានធ្វើដំណើរពីសហរដ្ឋទៅកាន់ទ្វីបអឺរ៉ុប ។ មិនយូរប៉ុន្មានបន្ទាប់ពីការទៅដល់ គោលដៅ កូនប្រុសអាយុ 13 ឆ្នាំម្នាក់បានចាប់ផ្ដើមឈឺ ។ ពីដំបូង ឪពុកម្ដាយបានគិតថាការហើមពោះរបស់គាត់ បានបណ្ដាលឱ្យមានការអស់កម្លាំងមកពីការជិះយន្តហោះដ៏យូរ ហើយគ្រួសារបានបន្តការធ្វើដំណើររបស់ខ្លួន ។

នៅពេលដែលថ្ងៃបានបន្តទៅមុខ ស្ថានភាពរបស់កូនប្រុសនោះមានផលកាន់តែអាក្រក់ ។ កំដៅកាន់តែក្ដៅឡើង ។ ឪពុកបានផ្ដល់នូវការប្រសិទ្ធពរជ័យដោយបព្វជិតភាព ប៉ុន្តែភ្លាមៗនោះ គ្មានការធូរស្បើយគួរឱ្យកត់សំគាល់ឡើយ ។

ប៉ុន្មានម៉ោងបានកន្លងផុតទៅ ហើយម្ដាយបានលុតជង្គង់នៅក្បែរកូនប្រុសរបស់នាង ដោយទូលអង្វរនៅក្នុងការអធិស្ឋានដល់ព្រះវរបិតាសួគ៌សំរាប់សុវត្ថិភាពរបស់ក្មេងប្រុសនោះ ។ ពួកគេបានចាកចេញឆ្ងាយពីផ្ទះ មកក្នុងប្រទេសដែលមិនធ្លាប់ស្គាល់ ហើយមិនដឹងពីរបៀបដើម្បីទទួលជំនួយខាងវេជ្ជសាស្ត្រទេ ។

ម្ដាយរូបនោះបានសួរកូនប្រុសរបស់នាង ប្រសិនបើវាចង់អធិស្ឋានជាមួយនឹងនាង ។ នាងបានដឹងថា ការរង់ចាំសំរាប់ពរជ័យដែលបានគិតទុកនោះមិនគ្រាប់គ្រាន់ទេ ពួកគេត្រូវតែធ្វើតាម ។ ដោយពន្យល់ថាពរជ័យដែលវាបានទទួលនៅតែមានឥទ្ធិពល នាងបានសុំឱ្យមានការទូលអង្វរម្ដងទៀតនៅក្នុងការអធិស្ឋាន ដូចដែលបានធ្វើដោយពួកសាវក ពីបុរាណថា "សូមទ្រង់ចំរើនសេចក្ដីជំនឿដល់យើង" (លូកា 17:5) ។ ការអធិស្ឋាននោះបានរួមបញ្ចូលនូវការអះអាង នៃការទុកចិត្តលើអំណាចបព្វជិតភាព និងការតាំងចិត្តតស៊ូវនៅក្នុងការធ្វើនូវអ្វីក៏ដោយ ដែលតំរូវឱ្យមានចំពោះពរជ័យនោះ ---ប្រសិនបើពរជ័យនៅពេលនោះ ស្របទៅនឹងឆន្ទៈរបស់ព្រះ ។ មិនយូរប៉ុន្មាន បន្ទាប់ពីពួកគេបានអធិស្ឋានដ៏សាមញ្ញនេះហើយ ស្ថានភាពរបស់កូនប្រុសនោះបានប្រសើរឡើង ។

ទង្វើរដ៏ស្មោះត្រង់របស់ម្ដាយ និងកូនប្រុសរបស់នាងបានជួយក្នុងការអញ្ជើញដល់អំណាចបព្វជិតភាពដែលបានសន្យា ហើយម្យ៉ាងទៀត បានបំពេញនូវតំរូវការដែលថា ចូរយើង "កុំជំទាស់ឡើយ ដោយព្រោះ [យើង] មើលមិនឃើញត្បិត [យើង] ពុំទទួលសាក្សីឡើយ លុះដល់ពេលក្រោយពីការសាកល្បងនៃសេចក្ដីជំនឿ [របស់យើង] សិន" (អេធើរ 12:6) ។ ដូចជាគុកដែលបានដាក់អាលម៉ា និងអាមូលេកមិនបានធ្វើឱ្យរលំចុះទៅដីទេ "លុះត្រាក្រោយពីសេចក្ដីជំនឿរបស់ពួកគេសិន" (សូមមើល អេធើរ 12:12-15) ដូច្នេះការព្យាបាលក្មេងប្រុសអាយុ 13 ឆ្នាំ រូបនេះពុំបានកើតឡើងឡើយ " លុះត្រាក្រោយពីសេចក្ដីជំនឿរបស់ពួកគេសិន" ហើយត្រូវបានសំរេចឡើង "ស្របតាមសេចក្ដីជំនឿរបស់គេក្នុងការអធិស្ឋានរបស់ពួកគេ" (គ និង ស 10:47) ។

## កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ

គំរូទីបីរបស់ខ្ញុំបង្ហាញលើសារៈសំខាន់នៃការយល់ដឹង និងការទទួលយកនូវឆន្ទៈរបស់ព្រះនៅក្នុងជីវិតរបស់យើង ។ កាលពីប៉ុន្មានឆ្នាំមុន មានឪពុកវ័យក្មេងម្នាក់ដែលជាមនុស្សសកម្មនៅក្នុងសាសនាចក្រកាលពីនៅក្មេង ប៉ុន្តែបានជ្រើសរើសផ្លូវ

ផ្សេងទៀតនៅក្នុងយុវវ័យរបស់គាត់ ។ ក្រោយពីការបំរើកងទ័ព គាត់បានរៀបការនឹងនារីដ៏ស្រស់ស្អាតម្នាក់ ហើយមិនយូរប៉ុន្មានកូនចៅបានកើតនៅក្នុងគ្រួសាររបស់ពួកគេ ។

មានថ្ងៃមួយ ដោយពុំបានដឹងជាមុន កូនស្រីតូចរបស់ពួកគេអាយុបួនឆ្នាំបានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង ហើយបានសំរាកនៅឯមន្ទីរពេទ្យ ។ ដោយការព្រួយបារម្ភ និងជាលើកទីមួយនៅក្នុងរយៈពេលជាច្រើនឆ្នាំ ឪពុករូបនោះបានលត់ជង្គង់ចុះអធិស្ឋាន សុំឱ្យជីវិតកូនស្រីរបស់ខ្លួនត្រូវបានសង្គ្រោះ ។ ប៉ុន្តែស្ថានភាពរបស់នាងកាន់តែដុនដាបទៅៗ ។ បន្តិចម្តងៗ ឪពុករូបនេះបានទទួលអារម្មណ៍ថា កូនស្រីតូចរបស់គាត់នឹងមិនរស់ឡើយ ហើយការអធិស្ឋានរបស់គាត់បានផ្លាស់ប្តូរបន្តិចម្តងៗ គាត់ពុំបានអធិស្ឋានសំរាប់ការជាសះស្បើយទៀតឡើយ ប៉ុន្តែសំរាប់ការយល់ដឹងវិញ ។ ពេលនេះពាក្យ " សូមតាមតែព្រះហឫទ័យទ្រង់វិញ" គឺជារបៀបនៃការទូលអង្វររបស់គាត់ ។

មិនយូរប៉ុន្មានកូនស្រីរបស់គាត់បានភ្លឹកស្មារតី ហើយឪពុកបានដឹងថាពេលវេលានៅផែនដីរបស់នាងមានតិចតួចណាស់ ។ ដោយបានការការពារជាមួយនឹងការយល់ដឹង ការទុកចិត្ត និងអំណាចដែលហួសពីសមត្ថភាពរបស់ខ្លួន ឪពុកម្តាយវ័យក្មេងរូបនេះ បានអធិស្ឋានម្តងទៀត ដោយសុំឱ្យមានឱកាសដើម្បីឱបក្រសោបនាងម្តងទៀត ខណៈដែលនាងនៅដឹងខ្លួន ។ ភ្នែកទាំងគូរបស់កូនស្រីនោះបានបើកឡើង ហើយដៃដ៏ទន់ខ្សោយរបស់នាងបានលាតសន្ធឹង ទៅរកឪពុកម្តាយរបស់ខ្លួនដើម្បីទទួលការឱបក្រសោបជាលើកចុងក្រោយបង្អស់ ។ ហើយបន្ទាប់មក នាងក៏បានផុតដង្ហើមទៅ ។ ឪពុករូបនេះបានដឹងថាការអធិស្ឋានរបស់ខ្លួនត្រូវបានឆ្លើយតប--- ដែល ព្រះវរបិតាគង់នៅស្ថានសួគ៌ដ៏សប្បុរសបានលួងលោមដួងចិត្តរបស់ពួកគេ ។ ឆន្ទៈរបស់ព្រះនឹងបានសំរេច---ហើយពួកគេបានទទួលនូវការយល់ដឹង ។ (យកលំនាំតាម H. Burke Peterson, “Adversity and Prayer,” *Ensign* ខែ មករា ឆ្នាំ 1974, 18) ។

ការសង្កេត និងទទួលយកនូវឆន្ទៈរបស់ព្រះនៅក្នុងជីវិតរបស់យើង គឺជាកត្តាដ៏សំខាន់នៃការសូមដោយចិត្តជឿនៅក្នុងអធិស្ឋានដែលមានអត្ថន័យ ។ ទោះជាយ៉ាងណាក៏ដោយ ការពោលពាក្យយ៉ាងសាមញ្ញថា " សូមតាមតែព្រះហឫទ័យទ្រង់វិញ" គឺមិនគ្រប់គ្រាន់ឡើយ ។ យើងម្នាក់ៗត្រូវការជំនួយរបស់ព្រះនៅក្នុងប្រគល់ឆន្ទៈរបស់យើងចំពោះទ្រង់ ។

"ការអធិស្ឋានជាទង្វើដែលឆន្ទៈរបស់ព្រះវរបិតា និងឆន្ទៈរបស់កូនបានធ្វើឱ្យមានទំនាក់ទំនងរវាងគ្នានឹងគ្នា" (Bible Dictionary, "Prayer" 752-753) ។ ការអធិស្ឋានដោយបន្ទាបខ្លួន ស្មោះត្រង់ និងតស៊ូ ជួយយើងឱ្យយល់ និងរៀបចំខ្លួនយើងឱ្យស្របនឹងឆន្ទៈនៃព្រះវរបិតាសួគ៌របស់យើង ។ ហើយនៅក្នុងកិច្ចការនេះ ព្រះអង្គសង្គ្រោះបានផ្តល់នូវគំរូដ៏ល្អឥតខ្ចោះ នៅពេលដែលទ្រង់បានអធិស្ឋាននៅក្នុងសួនច្បារគែតសេម៉ានី ថា : "ឱព្រះវរបិតាអើយ បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូលបង្គំទៅ ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ... ។ ហើយដោយទ្រង់កើតទុក្ខជាខ្លាំងបានជាទ្រង់អធិស្ឋានទទូចរឹតតែខ្លាំងឡើង" (លូកា 22:42, 44) ។

គោលបំណងនៃការអធិស្ឋានរបស់យើងពុំគួរមានដើម្បីបង្ហាញតារាងនៃការចង់បាន ឬបណ្តុំនៃការស្នើសុំឡើយ ---ប៉ុន្តែដើម្បីការពារខ្លួនយើង និងសំរាប់ពរជ័យផ្សេងទៀតដែលព្រះសព្វព្រះទ័យនឹងប្រទានឱ្យ ស្របទៅតាមឆន្ទៈ និងកាលវេលារបស់ទ្រង់ ។ រាល់ការអធិស្ឋានដោយស្មោះស្ម័គ្រ ត្រូវបានឮ ហើយឆ្លើយតបដោយព្រះវរបិតាសួគ៌របស់យើង ប៉ុន្តែចម្លើយទាំងឡាយដែលយើងទទួលអាចមិនមែនជាអ្វីដែលយើងរំពឹងទុក ឬអាចមិនកើតឡើងចំពោះយើងពេលដែលយើងចង់បាន ឬនៅក្នុងរបៀបដែលយើងរំពឹងទុកនោះឡើយ ។ សេចក្តីពិតនេះគឺជាភស្តុតាងនៅក្នុងគំរូទាំងបី ដែលខ្ញុំបានបង្ហាញអ្នកទាំងអស់គ្នានៅថ្ងៃនេះ ។

ការអធិស្ឋានគឺជាឯកសិទ្ធិ និងចំណង់ដ៏ស្មោះស្ម័គ្រនៃព្រលឹង។ យើងអាចធ្វើឱ្យហួសពីការអធិស្ឋានជាទំលាប់ ហើយខ្វះនូវការខិតខំ ហើយធ្វើនូវការអធិស្ឋានដែលមានអត្ថន័យ នៅពេលយើងសូមដោយចិត្តជឿ ហើយធ្វើតាមយ៉ាងត្រឹមត្រូវ នៅពេលយើងស៊ូទ្រាំដោយអត់ធ្មត់នៅក្នុងការសាកល្បងនៃសេចក្តីជំនឿរបស់យើង និងនៅពេលយើងឆ្លើយតប ហើយទទួលយកដោយបន្ទាបខ្លួនថា "កុំតាមចិត្តទូលបង្គំឡើយ សូមតាមព្រះហឫទ័យទ្រង់វិញ" ។

ខ្ញុំសូមធ្វើជាសាក្សីនូវធាតុពិត និងទេវភាពនៃព្រះវរបិតាដ៏អស់កល្បជានិច្ចរបស់យើង នៃព្រះរាជបុត្រាបង្កើតតែមួយព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងនៃព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំសូមធ្វើទីបន្ទាល់ថា ព្រះវរបិតារបស់យើងទ្រង់សណ្តាប់ ហើយឆ្លើយតបការអធិស្ឋានរបស់យើង។ សូមឱ្យយើងម្នាក់ៗព្យាយាមជាមួយនឹងការប្តេជ្ញាចិត្តដ៏មហិមាដើម្បីសូមដោយចិត្តជឿ ហើយតាមរបៀបនេះ ធ្វើឱ្យការអធិស្ឋានរបស់យើងមានអត្ថន័យពិតប្រាកដ។ ខ្ញុំសូមអធិស្ឋាននៅក្នុងព្រះនាមពិសិដ្ឋនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ អាម៉ែន។